ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ..១៦០៧៩.....អពដ

# សេចក្តីជូនដំណឹងស្តីពី

## ការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ដើម្បីបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ

**អគ្គនាយកដ្ឋានពន្ធដារ** ត្រូវការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាទាំងពីរភេទ ចំនួន **១០ រូប**
ដើម្បីបំពេញការងារ នៅ **CALL CENTER** នៃអគ្គនាយកដ្ឋានពន្ធដារ។

| មុខតំណែង | មន្ត្រី Call Center | ទីតាំង | អគ្គនាយកដ្ឋានពន្ធដារ |
|---|---|---|---|
| ថ្ងៃប្រកាស | ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ២០១៧ | ថ្ងៃផុតកំណត់ | ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១៧ |
| បេក្ខជនដែលជាប់ Short-Listed អគ្គនាយកដ្ឋានពន្ធដារនឹងជូនដំណឹងតាមរយៈទូរស័ព្ទ | | | |

### ភារកិច្ច និងការទទួលខុសត្រូវ

- ដោះស្រាយបញ្ហា និងឆ្លើយតបសំនួរ តាមរយៈទូរស័ព្ទ និងសារអេឡិចត្រូនិក ជូនអ្នកជាប់ពន្ធ
- ផ្តល់នូវសេវាអ្នកជាប់ពន្ធប្រកបដោយវិជ្ជាជីវៈ
- បញ្ចូលកិច្ចសន្ទនាទៅក្នុងប្រព័ន្ធគ្រប់គ្រង (CRM)
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលការងារប្រចាំថ្ងៃ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការចាត់តាំង

### លក្ខខណ្ឌជ្រើសរើស

- មានសញ្ញាបត្រកម្រិតចាប់ពីបរិញ្ញាបត្ររង ផ្នែកគ្រប់គ្រងធុរកិច្ច ទីផ្សារ ហិរញ្ញវត្ថុ រដ្ឋបាល-សាធារណៈ ឬសញ្ញាបត្រប្រហាក់ប្រហែល
- មានបទពិសោធន៍ការងារក្នុងវិស័យពន្ធដារយ៉ាងតិច ២ ឆ្នាំ
- មានសមត្ថភាពក្នុងការធ្វើការងារដោយឯករាជ្យ និងការងារជាក្រុម
- មានចំណេះដឹងក្នុងការផ្តល់សេវា និងការអនុវត្តន៍ជូនអ្នកជាប់ពន្ធទូទៅ
- មានជំនាញទំនាក់ទំនង ចរចា និង ផ្សះផ្សា ជាមួយអ្នកជាប់ពន្ធ
- មានជំនាញក្នុងការនិយាយ និងសរសេរ
- មានជំនាញក្នុងការដោះស្រាយបញ្ហាកម្រិតខ្ពស់ និង ពហុជំនាញ (Multi-task Skills)
- រួសរាយរាក់ទាក់ និងពេញចិត្តបំពេញសេវាកម្មដល់អ្នកជាប់ពន្ធ
- ជំនាញ កុំព្យូទ័រ (Microsoft Office: Word, Excel..., Internet and Email)
- មានឆន្ទៈក្នុងការបំពេញការងារ និងទទួលយកការបណ្តុះបណ្តាលផ្សេងៗ
- ភាសាអង់គ្លេស (កម្រិត មធ្យម)។

### ព័ត៌មាននៃការដាក់ពាក្យសុំបម្រើការងារ

បេក្ខជនទាំងពីរភេទដែលមានចំណាប់អារម្មណ៍ និងមានលក្ខណៈសម្បត្តិដូចបានរៀបរាប់ខាងលើ សូមផ្ញើប្រវត្តិរូបសង្ខេប ដោយភ្ជាប់រូបថតបច្ចុប្បន្ន និងភ្ជាប់មកជាមួយនូវសញ្ញាបត្រថតចម្លង ព្រមទាំងឯកសារផ្សេងៗទៀត តាមរយៈសារអេឡិចត្រូនិក ccs@tax.gov.kh ក្នុងករណីចាំបាច់ អគ្គនាយកដ្ឋានពន្ធដារ មានសិទ្ធិកែប្រែព័ត៌មានទាំងអស់ ដោយមិនចាំបាច់ជូនដំណឹងជាមុន។

ព័ត៌មានបន្ថែមសូមទំនាក់ទំនង នាយកដ្ឋានបុគ្គលិក និងរដ្ឋបាល ហិរញ្ញវត្ថុ នៃអគ្គនាយកដ្ឋានពន្ធដារ ដែលមានអាសយដ្ឋានៈ អាគារកែងមហាវិថីសហព័ន្ធរុស្ស៊ី និងមហាវិថីម៉ៅសេទុង សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។
ទូរស័ព្ទលេខៈ ០២៣ ៨៨៥ ៧៩១ រៀងរាល់ម៉ោងធ្វើការ

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ២០១៧
**អគ្គនាយកដ្ឋានពន្ធដារ**